## ការធ្វេសប្រហែស (negligence)

ជាទូទៅ បទល្មើសទាមទារនូវ ចេតនា ដែលជាធាតុផ្សំអត្តនោម័ត (*mens rea*) ក៏ប៉ុន្តែ ក្នុងករណីលើកលែងខ្លះ ធាតុផ្សំអត្តនោម័តនៃបទល្មើស ចែងតម្រូវត្រឹមកម្រិតការធ្វេសប្រហែស ហើយការទទួលខុសត្រូវព្រហ្មទណ្ឌ (criminal liability) ដោយសារការធ្វេសប្រហែសនេះ មានកម្រិតទាបជាងទង្វើដោយ ចេតនា។

ការធ្វេសប្រហែសមានពីរកម្រិតៈ កម្រិតស្រាល (mere/inadvertent) និងធ្ងន់ធ្ងរ (gross negligence)។ សម្រាប់កម្រិតទី១ អ្នកប្រព្រឹត្ត មិនបានដឹងអំពីហានិភ័យទេ តែខកខានមិនបានគោរពស្តង់ដារប្រតិបត្តិការងារ ដែលគេទទួលស្គាល់ (accepted standard of conduct) ហើយបង្កឲ្យមានផលវិបាកគ្រោះថ្នាក់។ ទី២. នេះ អ្នកប្រព្រឹត្តិដឹងអំពីហានិភ័យ ទោះបីជាយ៉ាងនេះក្តី កម្រិតនៃពិរុទ្ធភាពទាបជាងការខ្វីខ្វា (recklessness)។

ការធ្វេសប្រហែស ជាធាតុផ្សំអត្តនោម័ត ត្រូវបានទាមទារក្នុងបទល្មើសមួយចំនួននៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ (crime against humanity) និងក្នុងទម្រង់នៃការទទួលខុសត្រូវរបស់មេបញ្ជាការ (command responsibility)។ ក៏ប៉ុន្តែលុះត្រា មេបញ្ជាការ មានការធ្វេសប្រហែសធ្ងន់ធ្ងរចំពោះសកម្មភាពកូនចៅនៅក្រោមបង្គាប់ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 433-434)។